ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ១៥៣ ប.ក. សក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## ការកែសម្រួលអង្គភាពគ្រប់គ្រង និងតាមដានគម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីចំណែកផ្លូវជាតិលេខ ៤(ចំការហ្លួង) ដល់ ទីរួមខេត្តកោះកុង ក្រោមឥណទានសហប្រតិបត្តិការពីសាធារណរដ្ឋកូរ៉េ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន។

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

-បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់អោយប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ពីដៃគូអភិវឌ្ឍន៍។

-យោងសេចក្តីសម្រេចលេខ ៣៥៤៦ សសរ.សក ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងជួររាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា។

-យោងកំណត់ហេតុកិច្ចពិភាក្សា ស្តីអំពីគម្រោងលើកកម្រិតផ្លូវជាតិលេខ៤៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារ EDCF ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

-យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

## សម្រេច

**ប្រការ១៖** កែសម្រួលអង្គភាពគ្រប់គ្រង និងតាមដានគម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីចំណែកផ្លូវជាតិលេខ ៤

(ចំការហ្លួង) ដល់ទីរួមខេត្តកោះកុង ក្រោមគំណាទានសហប្រតិបត្តិការពីសាធារណរដ្ឋកូរ៉េ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **គួច ចាន់ភ្ញុសល** | រដ្ឋលេខាធិការ | ប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង |
| ២- ឯកឧត្តម | **គី សុនាត់** | អគ្គនាយកសាធារណការ | ប្រធានគម្រោង |
| ៣- លោក | **ស្ងួន គារិទ្ធ** | អគ្គនាយករងសាធារណការ | អនុប្រធានគម្រោង |
| ៤- លោក | **ហេង រ័ត្នពិសិដ្ឋ** | ប្រធាននាយកដ្ឋានផ្លូវថ្នល់ | អ្នកចាត់ចែងគម្រោង |
| ៥- លោកស្រី | **ហែម ផល្លី** | ទីប្រឹក្សាក្រសួង សកដ | ទទួលបន្ទុកគណនេយ្យ |
| ៦- លោក | **គាន់ ធីរ៉ា** | អនុប្រធាននាយកដ្ឋាន ហថវ | ទទួលបន្ទុកកិច្ចសន្យា |
| ៧- លោក | **ទេស តារារ័ត្ន** | មន្ត្រីខុទ្ទកាល័យ | ទទួលបន្ទុករដ្ឋបាល |
| ៨- លោក | **យូ ដារ៉ា** | អនុប្រធាននាយកដ្ឋានផ្លូវថ្នល់ | ទទួលបន្ទុកបច្ចេកទេស |
| ៩- លោក | **ជា ដារ៉ា** | អនុប្រធានការិយាល័យ នផថ | ទទួលបន្ទុកគម្រោងប្លង់ |
| ១០- លោក | **ឈុំ សុខ** | អនុប្រធានការិយាល័យ នផថ | សមភាគីទទួលបន្ទុកលទ្ធកម្ម |
| ១១- លោក | **លី សារ៉េត** | ប្រធានមន្ទីរ សកដ ខេត្តកោះកុង | សមភាគី |
| ១២- លោក | **លឹម សុខតៃ** | អនុប្រធានការិ.នៃ នហថវ | សមភាគី |
| ១៣- លោក | **ហ៊ាង សុខ្ញាឃុត្តិ** | មន្ត្រីខុទ្ទកាល័យ | សមភាគី |
| ១៤- លោកស្រី | **ម៉ុន សុគន្ធារ៉ា** | មន្ត្រីខុទ្ទកាល័យ | សមភាគី |
| ១៥- លោក | **ដួង ឆោមរតនៈ** | មន្ត្រីនៃនាយកដ្ឋានផ្លូវថ្នល់ | សមភាគី |

**ប្រការ២៖** អង្គភាពនេះមានភារកិច្ចគ្រប់គ្រង (Management) តាមដាន(Monitoring) និងសម្របសម្រួល (Facilitation) នៃការសិក្សា និងការអនុវត្តរាល់បណ្តាការងារពាក់ព័ន្ធគម្រោង។

**ប្រការ៣៖** សមាជិកនៃអង្គភាពដូចមានចែងក្នុងប្រការ១ ខាងលើត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងអនុវត្តភារកិច្ចតាមការប្រគល់របស់នាយកគម្រោង ។ សមាជិកផ្សេងៗបន្ថែមទៀតនៃអង្គភាពគម្រោងនេះត្រូវរៀបចំ និងតែងតាំងដោយនាយកគម្រោងតាមការចាំបាច់។

**ប្រការ៤៖** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥៖** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន សាមីខ្លួនដូចមានចែងក្នុងប្រការ១ និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**ស៊ុន ចាន់ថុល**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ